**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៣៥ **អយក.**សណន

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តវិធានការបង្ការជំងឺគ្រុនឈាម និងការកាត់បន្ថយ និងទប់ស្កាត់ការបង្កកំណើតសត្វមូសនៅតាមគ្រឹះស្ថានសិក្សា

ក្នុងគោលបំណងជំរុញការអនុវត្តវិធានការបង្ការជំងឺគ្រុនឈាម កាត់បន្ថយ និងទប់ស្កាត់ការបង្កកំណើតសត្វមូសនៅតាមគ្រឹះស្ថានសិក្សា ព្រមទាំងចូលរួមអនុវត្ត **វិធានការអន្តរាគមន៍របស់ក្រសួងសុខាភិបាល** ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ឱ្យចូលរួមអនុវត្តវិធានការដូចខាងក្រោម៖

- ត្រូវលុបបំបាត់ជម្រកដង្កូវទឹក ថ្លុកទឹក ឬសម្ភារៈដែលដក់ទឹក និងទីជម្រកមូសនៅក្នុងបរិវេណ និងជុំវិញបរិវេណគ្រឹះស្ថានសិក្សា
- ត្រូវលាងសម្អាតសម្ភារៈដែលដក់ទឹក ដូចជា ពាង អាងទឹក ថូផ្កា ចានទ្រជើងតុ ក្រឡ ធុង ខាប់ ជាដើម ដើម្បីផ្លាស់ប្តូរលាងសម្អាតជាប្រចាំ ឱ្យបានយ៉ាងតិចមួយដងក្នុងមួយសប្តាហ៍ ឬត្រូវគ្របគម្របឱ្យជិតល្អ
- កាប់ឆ្ការសម្អាតស្មៅស៊ុបទ្រុប ក្នុងបរិវេណ និងនៅជុំវិញសាលារៀន ឱ្យបានស្អាត
- ស្លៀកខោជើងវែង អាវដៃវែង និងស្រោមជើង ដើម្បីគ្របដណ្តប់រាងកាយឱ្យជិត (សម្លៀកបំពាក់គួរមានពណ៌ភ្លឺ)
- បើកទ្វារបង្អួចឱ្យមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់ ទ្វារនិងបង្អួច គួរមានសំណាញ់បើអាច
- ត្រូវប្រើថ្នាំបាញ់ ឬលាប កុំឱ្យមូសមកជិត
- ត្រូវសហការជាមួយបណ្តាញសុខាភិបាលតាមមូលដ្ឋាន ដើម្បីដាក់ថ្នាំបាណកយាដសម្លាប់ដង្កូវទឹក នៅក្នុងអាងទឹក ពាងទឹក កន្លែងស្តុកទឹក ឬចិញ្ចឹមកូនត្រីប្រាំពីរពណ៌នៅកន្លែងដែលអាចចិញ្ចឹមបាន
- ប្រសិនមានរោគសញ្ញាគ្រុនក្តៅខ្លាំងភ្លាមៗចាប់៣៩ទៅ៤០អង្សារ សូមទៅពិគ្រោះយោបល់ និងពិនិត្យព្យាបាលជាបន្ទាន់នៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត និងសូម **ទូរសព្ទមកលេខ ១១៥**
- ត្រូវមានទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានគ្រឹះស្ថានសិក្សាក្នុងការអនុវត្តវិធានការអនាម័យឱ្យបានខ្ជាប់ខ្ជួន

- ក្នុងករណីមានជំងឺរាតត្បាត ឬហានិភ័យសុខភាពក្នុងរដូវភ្លៀងនេះ សូមធ្វើការរាយការណ៍តាមរយៈបុគ្គលិកសុខាភិបាលនៅជិតបំផុត ឬសមត្ថកិច្ចពាក់ព័ន្ធនៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីដោះស្រាយ និងសង្គ្រោះជាបន្ទាន់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីអនុវត្តឱ្យបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។da.

ថ្ងៃអង្គារ ១៥រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំយុវជននិងកីឡា

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានអប់រំ
  *"ដើម្បីជូនជ្រាបជាព័ត៌មាន*
- រដ្ឋបាលរាជធានី ខេត្ត *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- អង្គភាពពាក់ព័ន្ធក្រោមឱវាទ *"ដើម្បីមុខការ"*
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត *"ដើម្បីមុខការ"*
- គ្រប់គ្រឹះស្ថានសិក្សា *"ដើម្បីអនុវត្ត"*
- កាលប្បវត្តិ
- ឯកសារ នា. សស